**សម្ភាសន៍ជាមួយ ដាង បូរី ហៅចាន់ ម៉ាលី ភេទស្រី អាយុ(ពុំបានបង្ហាញ)**
**មុខងារសម័យខ្មែរក្រហមៈ“ប្រធានកងចល័ត”**
**កើតនៅស្រុកស្ទឹងត្រែង ខេត្តស្ទឹងត្រែង**
**សព្វថ្ងៃរស់ ភូមិត្រពាំងប្រាសាទ ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ**
**ខេត្តឧត្តរមានជ័យ**
**ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៣**
**សម្ភាសន៍ដោយៈ ឌី ខាំបូលី**
**០០:៥៤ :០៦**
**២៥ ទំព័រ**

បូលីៈ ពី ៧៥ មក ៧៩ អ៊ំនៅម្តុំណាវិញ?

បូរីៈ សៀមប៉ាង។

បូលីៈ តាំងពី ៧៥ ឬក៏តាំពីពេលណាមក?

បូរីៈ ៧៥ហ្នឹង នៅស្គន់! ស្គន់ហើយបានឡើងទៅសៀមប៉ាង ។ ពេល៧៩ហ្នឹង នៅសៀមប៉ាង ហើយ ធ្វើកងចល័ត ។

បូលីៈ អ៊ំ អ្នកស្រុកខាងណាវិញ?

បូរីៈ នៅស្ទឹងត្រែង ។

បូលីៈ នៅស្ទឹងត្រែង?

បូរីៈ ចា៎ស!

បូលីៈ អូ៎! ខ្ញុំអ្នកក្រចេះ ។

បូរីៈ ចឹង?

បូលីៈ បាទ!

បូរីៈ បងខ្ញុំនៅរកចេះដែរ ។ គាត់ឈឺ គាត់មកអុជ ។

បូលីៈ គាត់នៅស្រុកអីគេ?

បូរីៈ នៅវត្តដំណាក់ ។

បូលីៈ អូ៎! វត្តដំណាក់ ផ្លូវទៅស្ទឹងត្រែង?

បូរីៈ វត្តដំណាក់ ឆ្លងទន្លេតើ!

បូលីៈ វត្តដំណាក់ខាងសម្បូរវិញហ៎?

បូរីៈ ចា៎ស!

បូលីៈ បាទៗ! ច្រលំម៉ុំនេះ អូរព្រះ! អូរក្រៀង!

បូរីៈ ចា៎ស!

បូលីៈ វគ្គដំណាក់! ខ្ញុំអត់ដែលបានទៅសោះខាងហ្នឹង។ ខ្ញុំទៅបានត្រឹមតែឆ្លងទន្លេ ចេញពីព្រែកប្រសប់ទៅ តែអត់ទៅដល់មុខសម្បូរ។ ចឹងអី អ្នកស្ទឹងត្រែង?

បូរីៈ ចា៎ស! ស្ទឹងត្រែង។

បូលីៈ ស្រុកអីគេអី?

បូរីៈ ស្រុកស្ទឹងត្រែង ខេត្តស្ទឹងត្រែង។

បូលីៈ កើតនៅទីរួមខេត្ត?

បូរីៈ ចា៎ស! នៅទីរួមខេត្ត។

បូលីៈ ហើយអីចូលបដិវត្តន៍មកតាំងពីឆ្នាំណា?

បូរីៈ តាំងពី៧២។

បូលីៈ ហេតុផលអីបានចូលកាលហ្នឹង?

បូរីៈ ចូលគេបង្កិវណ្ណៈតស៊ូ តអី(សើច)។

បូលីៈ មានអ្នកនាំចូលទេពេលហ្នឹង?

បូរីៈ ដល់ហ្នឹង ចលនាផុសផុល ចូលនៅក្នុងយុវជន កាលហ្នឹងយុវជន គេអប់រំថាមានអំពើជិះជាន់អីចឹងទៅណា ហើយនាំគ្នាចូលតស៊ូ ក៏នាំគ្នាចូលទៅណា។

បូលីៈ ពេលដែលអីចូលហ្នឹង ឈ្មោះអ៊ីអី! សារី សយ ហ្នឹង តាំងពីចូលបដិវត្តន៍ហ្នឹងអីដាក់ សារីសយដដែរ ឬយ៉ាងម៉េច?

បូរីៈ ទេ! ជាង បូរីតើ!

បូលីៈ ជាង បូរី ចុះពេលដែលចូលបដិវត្តន៍ហ្នឹង អីដាក់ឈ្មោះហ្នឹងដដែល ឬក៏ដូរឈ្មោះ?

បូរីៈ អឺ! ឈ្មោះអ៊ុំ នៅសំបុត្រនៅស្រុកកំណើត ចាន់ ម៉ាលី។ ដល់ចូលមកក្នុងជួរហ្នឹង ដូចថានៅក្នុងមន្ទីរហ្នឹងមានឈ្មោះ លី ដែរ ដល់ចឹងក៏កែដាក់ឈ្មោះថា រី ទៅ។ កាលសម័យប៉ុលពតហ្នឹង មានឈ្មោះថា រី នឹងណា។ ដល់តែមកឥលូវហ្នឹង អ៊ុំយកដូចថា យកខាងជីតា ខាងឪពុកមកដាក់វិញ ក៏ដាក់ ជាង បូរីទៅ។ ឈ្មោះវាបីដំណាក់។

បូលីៈ អត់មានឈ្មោះមួយមាត់ ឈ្មោះបដិវត្តន៍នឹងគេទេ?

បូរីៈ រី ហ្នឹងៗ!

បូលីៈ ឈ្មោះ រីហ្នឹងតែម្តង?

បូរីៈ ចាស! ពីមុនគេអត់មាននាមត្រកូលទេ បដិវត្តន៍នោះ។ ឈ្មោះតែ រីៗ ហ្នឹងឯង។

បូលីៈ ម៉េចបានជាគេអត់ប្រើត្រកូល អត់អីហ្នឹង?

បូរីៈ អត់ទេៗ!

បូលីៈ មួយមាត់ៗ!

បូរីៈ គេប្រើឈ្មោះតែ រីៗហ្នឹង ព្រោះឈ្មោះខ្ញុំ លី ដែរ ចាន់ ម៉ាលីចឹងណា។ គេហៅឈ្មោះ លីៗ ដល់មានមាក់នោះគេប្រុសនោះ ដល់ចឹងក៏ដូរឲ្យខ្ញុំឈ្មោះ រី វិញទៅ។ ជាប់ រី មករហូត គ្រាន់តែថែមនាមត្រកូល។

បូលីៈ ពេលដែលអីចូលហ្នឹង អីចូលដោយចិត្តឯងឬក៏?

បូរីៈ ចិត្តឯង ព្រោះចលនាវាផុលផុសចឹងណា។

បូលីៈ ចូលទៅជិបូងទៅធ្វើអ្វីដែលទៅអី?

បូរីៈ ចូលទៅជិបូង ទៅធ្វើការនៅក្នុងមន្ទីរគេ ក្នុងមន្ទីរ ប៉ុននៅក្នុងព្រៃនោះណាស្វាត់ ដើមឈើនៅក្នុងបន្ទាយគេ រួចទៅជីវភាពហ្នឹងអ្នកនៅក្នុងហ្នឹងដាំស្អីៗ ដាំស្រូវដាំពោត ដាំស្អីចឹងទៅណា! ហើយចូលទៅជិបូងហ្នឹង ហូបបាយលាយពោត អត់ហ៊ានមាត់មួយមាត់ទេ។ សុំម៉ែ ម៉ែខ្ញុំទៅតស៊ូនឹងគេហើយណា(សើច)។ ម៉ែខ្ញុំថា ឯងទៅតស៊ូនឹងគេកើតដែរ បើឯងទន់យ៉ាងនេះ ព្រោះពីសង្គមនោះខ្ញុំដើរៗ កាន់ចេកអាំងនោះដួលប្រោស របូតចេកអាំងនោះទៅមុខទៅគាត់ឃើញខ្ញុំវាទន់ ថាទៅពុំបានទេដឹង។ ខ្ញុំថាអត់ទេ បានម៉ែ! ដល់ចូលទៅចេះតែទ្រាំហើយ ព្រោះថាបានហើយ។ ហូបបាយលាយពោតលាយអី ការងារអីក៏ធម្មតា អាហ្នឹងក៏ដោយសារចិត្តបានគិតថា អូ៎! អានេះមកពីចិត្តទេ។ ចិត្តចង់ហើយចេះតែទម្លោះទម្លាយបានហើយណា។ យាមយប់ទៀត ដាក់វេនគ្នាយាម។

បូលីៈ អ៊ុំនៅក្នុងក្រុមយុវជន?

បូរីៈ អត់ទេ! ចូលមកមន្ទីរហើយ ចេញពីយុវជនហើយ។ យុវជនគឺនៅក្នុងភូមិ ក្នុងស្រុកយើង តែចូលដាច់ហើយ ចូលដាច់ខាងបដិវត្តន៍នឹងគេហើយ។

បូលីៈ មន្ទីរតំបន់ ឬក៏មន្ទីរ?

បូរីៈ មន្ទីរតំបន់។

បូលីៈ អូ៎! ខាងមន្ទីរតំបន់ចឹងតែម្តង! ស្ទឹងត្រែងតំបន់អីចេះ?

បូរីៈ តំបន់អ៎! តំបន់អីចេះ! តំបន់ ជ-៦។

បូលី៖ តំបន់ ដ-៦?

បូរី៖ ចា៎ស!

បូលី៖ គេមានលេខគេទេ?

បូរី៖ តំបន់ ដ-៦ ហ្នឹងឯង។

បូលី៖ តំបន់ ដ-៦ ស្ទឹងត្រែង តំបន់៤០៥ ។ មានលេខកូដអីទេអ៊ំ, តំបន់?

បូរី៖ លេខកូនហ្នឹងហើយ ដ-៦ ។

បូលី៖ ដ-៦ ហ្នឹង គេហៅតំបន់ស្ទឹងត្រែងតែម្ដងណ៎?

បូរី៖ ចា៎ស! ពេលចូលដំបូងនោះ អ៊ំធ្វើជាកងចល័ត អូ៎! អត់ទេក្រុមសិល្បៈ។ អ៊ុំអ្នកបង្រៀនសិល្បៈ។ គេដើររាំ ដើរច្រៀងជាក្រុមៗចឹងទៅដូចល្ខោន ចឹងទៅណា៎។ ហើយពីហ្នឹង បានចូលជាកងចល័ត។ កងចល័តហើយ បាន៧៩នោះទៅលើភ្នំបណ្ដោយ។

បូលី៖ ចុះច្រៀងរាំ យើងច្រៀងបទអីទៅអ៊ំ?

បូរី៖ ច្រៀងបទបដិវត្តន៍យើងទៅណា!

បូលី៖ ពីណាអ្នកតែងឲ្យច្រៀង?

បូរី៖ ខាងអង្គការគេហ្នឹង! គេច្រៀងមក ចុះគេមានវិទ្យុដាក់ បទចម្រៀងហ្នឹងទៅ គេមានយកមកពិនិត្យខ្លឹមសារគេត្រូវធ្វើជើង ធ្វើដៃ ធ្វើអីយ៉ាងម៉េចៗ យើងច្នៃខ្លួនឯង។

បូលី៖ ពេលហ្នឹង អើ! គណៈតំបន់គេឈ្មោះអី?

បូរី៖ ឈ្មោះ ប៊ុត។

បូលី៖ ហ្នឹងមេធំហើយអ៊ុំ?

បូរី៖ មេធំ!

បូលី៖ ចុះអនុរបស់គាត់?

បូរី៖ ឈ្មោះ វ៉នៗ ។

បូលី៖ អ៊ុំមានដឹងថាមន្ទីរភូមិភាគគ្នាសានហ្នឹងនៅស្ទឹងត្រែងហ្នឹងទេ?

បូរី៖ អត់ដឹងទេ! មិនចាប់អារម្មណ៍ ព្រោះរយៈហ្នឹងទាល់តែគេធ្វើការធំដុំ បានគេដឹងអាភូមិភាគគេយ៉ាងម៉េច អីយ៉ាងម៉េច យើងត្រឹមតែកងចល័តមិនដឹងទេ។

បូលី៖ អ៊ុំ មានដែលឮឈ្មោះតាយ៉ា?

បូរី៖ ដឹងតើ! តា យ៉ា ។

បូលី៖ ណៃ សារ៉ាន់ ហៅ យ៉ា?

បូរី៖   តា យ៉ាៗ! ហ្នឹងគណៈភូមិភាគគេហើយ ហើយគេចាប់គាត់ទៅ ។

បូលី៖  ដល់គេចាប់តា យ៉ាហ្នឹងទៅ ពីណាឡើងជំនួស?

បូរី៖   អត់ដឹង!

បូលី៖  ដែលពូឈ្មោះ តា វ៉ន?

បូរី៖   អ៊ូ! តា វ៉ន! ពូ!

បូលី៖  អ៊ុំ ណេង គាត់ត្រកូលគាត់ឈ្មោះ អ៊ុំណេង ហៅ វ៉ន?

បូរី៖   ហ្នឹងហើយ ហៅវ៉ន ។ វ៉ន នឹង ដឹងគាត់ស្លាប់ហ្នឹងចង្កក ។

បូលី៖  ចឹងអេ៎?

បូរី៖   ដូចពូថាចឹង! ក្រែងមិនច្បាស់ ។

បូលី៖  ពូសួរថាស្លាប់ដោយចង្កក?

បូរី៖   ចា៎ស!

បូលី៖  ក្រោយមកពីណាគ្រប់គ្រងភូមិភាគ ពេលតាវ៉នស្លាប់ទៅ?

បូរី៖   អត់ដឹង! ខ្ញុំស្គាល់តែគណៈតំបន់ខ្ញុំ ។ គេខាងលើគេរៀបរយ គេពុំប្រាប់យើងទេ ។

បូលី៖  ស្គាល់តែ តា ប៊ុត ហ្នឹងទេអី?

បូរី៖   ស្គាល់តែ ប៊ុត ហ្នឹង គណៈតំបន់ហ្នឹង ។

បូលី៖  គណៈតំបន់ស្អីងគ្រែង?

បូរី៖   ក្រោយមកតាវឿន យើងហ្នឹង ។

បូលី៖  តាវឿនដែរ?

បូរី៖   ចា៎ស! ស្គាល់តាវឿនដែរ ។

បូលី៖  តាវឿនណាគេអី?

បូរី៖   តាវឿន នៅអន្លង់វែងយើងហ្នឹង! តាវឿនទាហានហ្នឹង ប្រពន្ធឈ្មោះ រ៉ន នោះ ។

បូលី៖  បាទ! ស្គាល់ តាវឿន តាប៊ុត?

បូរី៖   គេយកតាវឿនទៅហ្នឹង តាប៊ុតឡើង ។

បូលី៖  ចឹង តាប៊ុត ទី១ តាវឿនទី២?

បូរី៖   នឹងគណៈតំបន់ណា!

បូលី៖  នៅនេះរហូតប្រហែលដល់៧៩តែម្តង?

បូរី៖   ចា៎ស! ៧៩ ដាច់ ។

បូលីៈ ចុះអ៊ីពេលណាបានទៅសៀមប៉ាង ដល់ពេលចេញពីមន្ទីរតំបន់ទៅ?

បូរីៈ ចូលដំបូង ចូលមន្ទីរសិល្បៈ សិល្បៈហើយបានទៅសៀមប៉ាង ទៅធ្វើចល័តនៅសៀមប៉ាង ប៉ុន ដូចភ្លេចឆ្នាំបាត់ហើយ ។

បូលីៈ ចេញពីចល័ត?

បូរីៈ ចេញសិល្បៈទៅកងចល័ត ។ កាលធ្វើសិល្បៈនៅស៊ឹងត្រែងដែរហ្នឹង អស់ពីនៅស៊ឹងត្រែងទៅនៅឯកាកុន អាហ្នឹងហើយបានធ្វើកងចល័ត ។

បូលីៈ ចល័តទៅដល់សៀមប៉ាង?

បូរីៈ ចាស!

បូលីៈ បញ្ជូនទៅបានឆ្ងាយម្ល៉េះអ៊ី?

បូរីៈ អើ! គេឲ្យទៅ ចេះតែទៅ ។

បូលីៈ ធ្វើអីគេនៅហ្នឹង?

បូរីៈ ធ្វើកងចល័ត ។

បូលីៈ ប៉ុនគេឲ្យធ្វើកិច្ចការអ្វីខ្លះ?

បូរីៈ ធ្វើទំនប់ ។

បូលីៈ លើកទំនប់ ជីកប្រឡាយ?

បូរីៈ មួយសារហ្នឹងវាលំបាកច្រើនដែរ ព្រោះកងចល័ត មនុស្សជាង១០០នាក់ ទាំងស្រីទាំងប្រុស ហើយយើងទៅនៅក្នុងចំណោម៧០ជាង និយាយចឹងខុសអត់?

បូលីៈ អត់អីទេ! វាជារឿងកាពិតរបស់អ៊ី ។

បូរីៈ ដល់ចឹងខាងនោះគេប្រកាន់ពូជសាសន៍ដែរណា ។

បូលីៈ ខាងជនជាតិ?

បូរីៈ គេនៅសហករណ៍គេនោះ យើងកងចល័តត្រូវទៅជួយសហករណ៍ ។ ដឹងតែព្រឹកឡើង ម៉ោង៥ មិនទាន់ទេប្រៀងអាស្អីគេនោះ ក្រោកឡើងមកហៅគ្នាទៅ មិនបានស៊ីបាយព្រឹកឯណា គ្មានអីទេ ទៅលើកទំនប់ ថ្ងៃឡើងចេញមកបានមួយក្អែតចេញមក ហើយចូលវិញហើយ ល្ងាចចេញទៅ ហើយទឹកឆ្ងាយទៀត ទំនងជា២គីឡូ ។ រួចហើយខ្ញុំសំណូមពរថា ឥឡូវទឹកហ្នឹង ដូចថាមិនអី ក៏ហើចុះកងចល័តហ្នឹង សុំតែថាឲ្យតែមានទឹកដឹកដាក់ទឹក មួយធុង ពីរធុងទៅព្រោះគេមាន មធ្យោបាយ មានរទេះមានអីដឹកលឿនចឹងណា យើងវាអត់ ។ ដល់សំនូមពរចឹងទៅក៏ពុំពាក្យ

មួយ ពាក្យពីរគេថាខ្ញុំនេះទំនាស់ជាមួយវាហ្នឹងចឹងតើ! គេជៀលថា ព្រោះកាលនោះ ការគ្រប់គ្រងនៅខាងគេទាំងអស់ ។

បូលីៈ ហើយទំនប់ដែលអ៊ំលើក ឈ្មោះអីគេអ៊ំ?

បូរីៈ ទំនប់ តា ខ្មៅ ។

បូលីៈ តា ខ្មៅ?

បូរីៈ ចាស!

បូលីៈ មិនដែលឮ ឈ្មោះនេះទេ?

បូរីៈ ទំនប់តា ខ្មៅ! នៅ សៀម ប៉ាង ។

បូលីៈ មានតែមួយ ឬក៏មានច្រើនជាងនេះ?

បូរីៈ មានពីរ ដូចជានៅទំនប់ អូរពូកនេះមួយ ។ មុននៅតាខ្មៅ គឺទំនប់ អូរពូក នៅខាង កាកុនហ៉ែ ចង់វង្វេងអស់ហើយ ។

បូលីៈ អ៊ំនៅលើកទំនប់នេះរហូត ដល់វៀតណាមវាយចូល?

បូរីៈ ចាស! លើកទំនប់ផង ជួយដើរធ្វើស្រូវប្រជាជនផង ។ គេត្រូវការ គេរកយើងទៅចឹងទៅណា ។

បូលីៈ ដល់លើកទំនប់ ជួយធ្វើស្រែធ្វើអីចឹងទៅ វៀតណាមវាយចូលមកក៏រត់បាត់ចឹងទៅ?

បូរីៈ ចាស!

បូលីៈ អ៊ំរត់តាមណា?

បូរីៈ រត់តាមសៀម ប៉ាង មិនដឹងជាទៅខាងណាខាងណី អ៊ំមិនស្គាល់ទេ ដឹងតែថាឆ្លងទឹកប៉ុន្មានទន្លេនោះ ។ ឆ្លងដល់យប់ចឹងប្រតាយគ្នាឡើងចឹងទៅ ។

បូលីៈ ឆ្លងហ្នឹង យើងជិះទូក ឬក៏?

បូរីៈ អត់ទេ! ឆ្លងទឹកតែម្តងណា ។

បូលីៈ ខែអី?

បូរីៈ ខែហ្នឹង ខែវាគោកផង ខែប្រាំង មិនដឹងជាខែប៉ុន្មានទេ ។

បូលីៈ ខែ១?

បូរីៈ ខែគេច្រូតស្រូវ នោះហើយខែគេច្រូតស្រូវ ។ កាលខ្ញុំរត់នោះខែប៉ុន្មាន ១២ ឬក៏១ទេដឹង?

អ្នកជិតខាងៈ ១២ ។

បូលីៈ ១២ ឬខែ១!

បូរីៈ អាចប៉ុណ្ណឹងឯង! ឆ្លងទឹក ឆ្លងអីទៅ ។

បូលីៈ អឹហែលឆ្លងទន្លេអី ឬក៏យ៉ាងម៉េច?

បូរីៈ ហែលតិចៗ រួចហើយគោក ច្រើនតែគោក ត្រឹមនេះៗ បេះតែនាំគ្នាទៅហើយ ។

បូលីៈ អត់មានកាន់ ឬស្សី ឬក៏កង់ឡានទេ?

បូរីៈ អត់ទេ! គេនាំទៅកន្លែងគោក មិនទៅទីណាបើនៅកន្លែងគោកល្អ វាមានទឹកដែរ តែវាមិនជ្រៅ ។

បូលីៈ ទន្លេវាធំដែរ?

បូរីៈ ទន្លេអត់ធំប៉ុន្មានទេ តូចតែមួយ ។

បូលីៈ អាចគោកៗ?

បូរីៈ ចាស! មានអ្នកខ្លះទៅ តាមក្រោយខ្ញុំហ្នឹងឆ្លងទឹករហូត ធ្វើក្បូនធ្វើអីឆ្លងណា ឆ្លងអាខ្លះឡើងទៅដល់គាំង ដៃគាំងជើង ដោយសារទឹករងាហ្នឹង ។

បូលីៈ នៅខែ១២ ខែរត្រជាក់ ខែកត្តិក?

បូរីៈ គេទៅតាមក្រោយៗ ពុំមែនខែហ្នឹងទេ អាចវស្សា ទៅតាមដំណាក់ៗវា មិនមែនទៅទាំងអស់គ្នាទេ ទៅពួននៅក្នុងព្រៃ ។

បូលីៈ ហើយអឹ មានគេនាំទៅ ឬក៏យ៉ាងម៉េច?

បូរីៈ គេនាំទេណា! ចុះយើងជាអន្តភាពដែរ! យើងគេនាំទៅ ។

បូលីៈ មេអឹ អ្នកនាំ ឬក៏ជានរណា?

បូរីៈ មិនដឹងជានរណា ពីណែ មេនាំថាឲ្យចេញគឺចេញ លើកនាំគ្នាចេញតែម្តង មានគេនាំ ។ នាំមកដីថៃណា នាំមកម៉ុំពាហ្នឹង ។

បូលីៈ មេកងចល័តអឹពីណាគេ?

បូរីៈ ខ្ញុំហ្នឹងឯង!

បូលីៈ អឹប្រធានកងចល័ត?

បូរីៈ ចាស!

បូលីៈ កងចល័តតំបន់?

បូរីៈ តំបន់!

បូលីៈ នារី ឬក៏បុរស?

បូរីៈ លាយគ្នាទាំង នារី ទាំងបុរស ។

បូលីៈ ប៉ុន្មានអីថា១០០នាក់ នៅក្នុងកងចល័តអី?

បូរីៈ ជាង១០០ប៉ុន្មាន ភ្លេចអស់ហើយ ច្រើនដែរ ។

បូលីៈ អ៊ីធ្វើដំណើររយៈពេលប៉ុន្មាន បានមកដល់មុំ៣?

បូរីៈ ដេកប៉ុន្មានយប់ទេនេះ!

បូលីៈ មកតាមផ្លូវនេះ ដើរ ឬក៏មានឡានជិះ?

បូរីៈ ដើរ! ដើររហូត ដល់លើភ្នំ ។

បូលីៈ ឆ្ងាយដែរ ។

បូរីៈ ឆ្ងាយ! កាត់ដីលាវផង អីផង ដឹងខ្ញុំមិនដឹងដែរ ។

បូលីៈ បើសៀម ប៉ាង យើងនៅជិតព្រំដែនលាវ?

បូរីៈ ចាស!

បូលីៈ សៀម ប៉ាង?

បូរីៈ ពីសៀម ប៉ាង មកដូចឆ្លងដំណាលគ្នា នាំគ្នាមកទីណាទេ ។

បូលីៈ ល្បាក់ខោន ល្បាក់អី មុំហ្នឹង?

បូរីៈ ដឹង! មុនហ្នឹងឆ្លងផ្លូវមួយៗ លូនក្រាបៗ ក្លាចទាហាន ទៅដល់លើយប់បានឆ្លង ។

បូលីៈ អត់ឆ្លងពេលថ្ងៃទេ?

បូរីៈ អត់ទេ! ដូចថាពេលយើងឆ្លងផ្លូវ ទុកពេលល្ងាចក្លាចហ្នឹងឯងឆ្លង! ឆ្លងទាំងយប់នោះឯង ។

បូលីៈ យើងឆ្លងចឹងរបស់ របស់យើងគិតយ៉ាងម៉េចទៅ?

បូរីៈ ប៉ុណ្ណះៗ កម្មសិទ្ធសមរម្យ ។

បូលីៈ កម្មសិទ្ធសមរម្យ គេប្រើពាក្យកម្មសិទ្ធសមរម្យមានដែរ?

បូរីៈ កាលនោះអាវ២កំប្លេម្នាក់ហ្នឹង ។

បូលីៈ ពាក្យនេះពីរោះដល់ហើយ អានេះបើកុំតែសួរអ៊ីអត់ដឹងទេ ។ តាមការពិតមួយសម្ភាសន៍នេះ បើសិនជាបានមួយពាក្យក៏បានដែរ ។

បូរីៈ កាលហ្នឹងមានតែទៃអង្ករមានតែអីចឹងទៅណា មានស្អីទេ ចានឆ្នាំងអីចែកគ្នា កាន់ម្នាក់តិចៗ ។

បូលីៈ សមរម្យមានទៃអង្ករមួយ ហើយរបស់របរ ដូចជាខោអាវ!

បូរីៈ ខោអាវ១កំប្លេ ២កំប្លេហ្នឹង មានអីច្រើន ។

បូលីៈ ចានឆ្នាំងអី?

បូរីៈ ចានឆ្នាំង មនុស្សច្រើនចែកគ្នា កាន់ទៅ ។

បូលីៈ អំបិលមានទេ អំបិល?

បូរីៈ មាន! ពេលចេញទៅត្រៀមអស់ហើយ ទាំងអំបិល ទាំងអី! នៅតាមផ្លូវ យើងហូបក្តូចមួយសារ ។

បូលីៈ អង្ករយើងយកតាមខ្លួនទៅហ្នឹង អត់ប្រើទេ?

បូរីៈ ប្រើ! តែ មិនដល់ទិសដៅ ទៅចឹងមួយទៅមួយដំណាក់ឈប់នៅទីណា ធ្វើក្តូច ធ្វើ អីតទៅទៀតណា ដល់ចុងក្រោយយើងមានស្ពាយសុទ្ធតែក្តូចទេ ហើយទៅដល់ស្លឹកព្រិច ។ ដល់ចុងក្រោយហ្នឹងក្តូច ហើយហ្នឹង ព្រិចបរបរចូលគ្នាទៅឆ្ងាញ់ ស្លឹកព្រិចយើងហ្នឹងនា ។

បូលីៈ វេទនាណាស់ នៅតាមផ្លូវ?

បូរីៈ អេ៎ វេទនា! មានស្អី ដើររហូត ។

បូលីៈ ហើយអញ្ចឹង សម្រាកម៉េចទៅ ពេលយប់?

បូរីៈ សម្រាកយប់ អង្រឹង អ្នកអត់អង្រឹងដីតើ! ប៉ុនកងចល័តខ្ញុំមានអង្រឹង ។

បូលីៈ ចងតាមដើមឈើអញ្ចឹងទៅ?

បូរីៈ ចង!

បូលីៈ មានកងទ័ពអីវៀតណាមបាញ់ ព្រោះឃើញកន្លែងយើងដើរល្បាតអីអញ្ចឹងបាញ់ដែរទេ?

បូរីៈ ទៅរកណា! យើងពួនវារហូត ។

បូលីៈ មានទល់គ្នាម្តងម្កាលទេ?

បូរីៈ អត់បានជួប ។ ប៉ុនគ្រួសារខ្ញុំស្លាប់ដោយសារវា នៅសៀមប៉ាងលើទៅទៀត ដើរទៅធ្វើការណាហើយវាបាញ់ ។ គាត់មាននិរសាដែរ ប៉ុន្តែអត់មាននិរសារទៅទេ គាត់ដើរមុន គាត់ដើរមុនអញ្ចឹងទៅវា ស៊ីប៉ះចំអាកម្ភាំងក្រោយ បកមកក្រោយ ។

បូលីៈ គាត់ធ្វើអ្វីគ្រួសារអឺ?

បូរីៈ ធ្វើប្រធានកងវរៈ ។

បូលីៈ វរៈតូច ឬក៏ធំ?

បូរីៈ តូច ។

បូលីៈ គាត់ឈ្មោះអីគេ?

បូរីៈ ឈ្មោះ ណែត!

បូលីៈ នៅក្នុង កងពលលេខប៉ុន្មាន?

បូរី៖ អត់ដឹងទេ! ដល់គេមកបញ្ចូលចូលព្រៃហើយ មិនដឹងជាកងពលលេខប៉ុន្មានទេ អត់ដឹងទេ ហ៊ូ ៨០១ ។

បូលី៖ ៨០១ របស់តា០៥?

បូរី៖ ហ្នឹងហើយ! ៨០១ហ្នឹង ។

បូលី៖ ប៉ុនវៀតណាមដែលបាញ់គាត់ហ្នឹង បាញ់នៅពេលដែលកំពុងរត់ ឬក៏នៅក្នុង?

បូរី៖ អត់ទេ! គាត់ដើរ ដើរទៅដូចថា ដើរទៅធ្វើការអញ្ចឹងណា ដើរទៅក៏ ស៊ីទៅ ហើយកម្លាំងពួកខ្ញុំដែលនៅជាមួយគាត់ស្រីៗហ្នឹងទៅជាមួយដែរ ប៉ុន្តែដើរក្រោយ ដើរក្រោយអញ្ចឹង អ្នកខ្លះសែងធុងទៅរកកន្លែងក្តួច ចង់រកក្តួច ដល់ពេលគេ ពុកាំភ្លើង អាអ្នកក្រោយគេបកមកក្រោយវិញ ហើយគេក៏រួចខ្លួនទៅ បាតតែគាត់ទៅហ្នឹងណា ។

បូលី៖ ពេលធ្វើដំណើរតាមផ្លូវហ្នឹងមានអ្នកដែលស្លាប់ដោយសារជំងឺទេ?

បូរី៖ អត់!

បូលី៖ ដាច់បាយ ដាច់ទឹកអី?

បូរី៖ អត់! ដាច់បាយ គេស៊ីដំឡូង ដំឡូងគល់ចេក អត់មែនទែន ។

បូលី៖ យើងមានចូលតាមភូមិអីដើម្បីសុំប្រជាជនហូបអាហារអីដែរទេ ពេលធ្វើដំណើរហ្នឹង?

បូរី៖ អត់! ធ្វើដំណើរទៅមុំពាហ្នឹង?

បូលី៖ បាទ!

បូរី៖ អត់! អត់មានចូលទេ ។ ព្រៃហូត!

បូលី៖ ហើយអត់មានជួបសត្វសាហាវទេអីអ៊ឹ?

បូរី៖ អត់អីដែរ ។

បូលី៖ ព្រោះកាលហ្នឹងយើងនៅសម្បូរសត្វនៅឡើយតា ខ្លា ដំរីអីទេ?

បូរី៖ ចាស! សម្បូរណ៍ ។ បើថានៅព្រៃ តិចៗបានដំរី បានឈ្លូស បានទន្សោងអីចឹងទៅណ៎ ។ បានមួយហូបៗ ។ គេយកខ្លាញ់ទន្សោងហ្នឹងទៅ ក្តួចយើងណា ផ្អាប់ៗយកទៅលីងជាមួយអាខ្លាញ់ទន្សោងហ្នឹងឆ្ងាញ់ណាស់ ។

បូលី៖ រែកងពុលអីអ៊ឹ?

បូរី៖ ពុល! ពេលខ្លះធ្វើអត់ទាន់ ពុលដែលហ្នឹងណា ។ ដូចថាយើងលាងអត់ជ្រះ វាក្រទឹកនោះមួយកន្លែងដែលខ្ញុំទៅហ្នឹង មានតែទឹកត្រពាំងមួយ ហើយនាំគ្នាទៅត្រាំទឹកជាន់ទឹកហ្នឹង ។ ដល់ពេលវាអត់មែនទែនហ្នឹង បន្ទាន់ៗហ្នឹងដូចថាក្តួចហ្នឹង គេយកទៅគួសហើយស្ងោរ ស្ងោរ

ហើយយកទៅត្រាំទឹកអាហ្នឹងច្រើនតែពុល ។ បើពុលក្ដួច ពុលបើធ្វើទុកខ្លាំង ក្ដួចចង្អោលដែរ ពុលតិចៗ ងងុយដេក ។

បូលីៈ ហើយអ្នកដែលនាំផ្លូវហ្នឹង ពីណាគេ? កងទ័ព ឬក៏ជាប្រជាជនសាមញ្ញធម្មតាទេ?

បូរីៈ មើលទៅអាចជាកងទ័ព ដូចថាខាងស្រុកគេ ខាងស្រុកគេនាំ ។

បូលីៈ មួយក្រុមដែលមាន ពេលដែលអ៊ីធ្វើដំណើរទៅ ប្រហែលជាប៉ុន្មាន?

បូរីៈ ច្រើន!

បូលីៈ ចូលរយទេ?

បូរីៈ រយ! ពួកខ្ញុំរយជាងហើយ ។

បូលីៈ យើងកាត់ព្រៃ ច្រើនដែរ ។ ហើយធ្វើម្ដេច បានដឹងថាផ្លូវនោះឡើងទៅមុំពាអ៊ី?

បូរីៈ ចុះអ្នកគេនាំនោះ យើងដើរតាមក្រោយមានទៅដឹងអី ដើរទៅឃើញលាវស ឃើញបាយគេ អើយឆ្ងាញ់ៗ ចុះយើងហូបតែក្ដួចនោះ ។

បូលីៈ ចុះអ៊ីទៅលាវសនោះ?

បូរីៈ លាវស ប្រវត្តិចលនាតស៊ូ ពួកលាវហ៎! លាវសថៃសហីនោះ មួយសារហ្នឹងបានហ្នឹង ។ វានៅតាមផ្លូវហ្នឹង បែបគេមានការទាក់ទ្ធាទេដឹង អត់មានធ្វើអីគ្នាទេ ប៉ុន្តែពួកហ្នឹងគេនៅតែអញ្ចឹង មានបាយហូបណា ដាំបាយមួយកំដុះកំដ្ឋា យើងឃើញហ្នឹងល្មមតែថា នឹកឃើញថាឡើងលើភ្នំ មិនបាច់មានអីហូបក៏បានដែរឲ្យតែមានបាយហូប មានអន្លុរដាំ ប៉ុណ្ណឹងណា បំណាច់ថាវាដាច់បាយយូរពេក ហ្នឹងហើយគិតឃើញអញ្ចឹង ។

បូលីៈ ប្រហែលជាអ៊ីដើរតាមដីវាល បានៗជួបលាវស?

បូរីៈ អ៊ឹអត់ដឹង! ជំនាន់ហ្នឹងចេះតែនាំទៅហើយ មិនបានយកចិត្តទុកដាក់អីណាបើ បារម្ភខ្លួនផង ភ័យខ្លាចផង ។

បូលីៈ បាទខ្ញុំគ្រាន់តែសង្ស័យទេ ព្រោះសៀម ប៉ាង ជាប់ហ្នឹងដីលាវតែម្ដង ហើយយើងដើរពីសៀម ប៉ាងទៅមុំពាហ្នឹង ប្រហែលជាកាត់តាមដីលាវហើយមើលទៅ?

បូរីៈ បែបដឹង!

បូលីៈ បាទ! ជួបលាវស លាវអីហ្នឹង?

បូរីៈ ចា៎ស!

បូលីៈ ពេលដែលទៅដល់ មុំពាហ្នឹងយ៉ាងម៉េចទៀតទៅអ៊ី របៀបរៀបចំយ៉ាងម៉េចទៅអ៊ី?

បូរីៈ អ៊ំ គេរៀបចំតាមកងពល ។

បូលីៈ អឺ នៅកងពលណា?

បូរីៈ កងពល៨០២! មាន៨០២,៨០១, មានខាងភូមិភាគកណ្ដាល, មានស្អីចឹងទៅណា នៅតាមម្តុំៗចឹងទៅ ។

បូលីៈ ៨០២នរណាគេប្រធានកងពល?

បូរីៈ តាឆន! គាត់ស្លាប់ហើយឥលូវ ។

បូលីៈ អញ្ចឹងអឺ រស់នៅម្តុំពាហ្នឹង គេរៀបការរស់នៅតាមកងពលនោះទៅ?

បូរីៈ ចាស! តាមកងពល ។

បូលីៈ គេមានផ្ដុំទៅតាមវរសេនាធំ វរសេនាតូចទេ? ថាវរសេនាធំនៅក្នុងនេះទៅ ឬម្តុំនោះទៅ?

បូរីៈ វាអាចដែរ ព្រោះតាមកងពលគេសួរហៅគ្នា ដូចថាត្រូវការហៅកម្លាំងចុះសមរភូមិអី គឺងាយស្រួលណា គេនៅតាមវរគេដែរ ។

បូលីៈ ដល់តែយើងហូបក្លួច ដាច់បាយដាច់ទឹកយូរអញ្ចឹងពេលទៅដល់ម្តុំពាភ្នាម គេមានរៀបចំម្ហូបអាហារឲ្យយើងទេ?

បូរីៈ ហ៊ូ! អាហារសម្បូរណ៍វិញ ដឹកមកទាំងឡានៗ ។ ទាំងអំបិអង្ករ ទាំងពីមី ត្រីខ អាកំប៉ុងសាច់អី កំប៉ុងអី ស្ករអីអត់ខ្វះទេ ត្រីកម៉ុង ប្រហុក ចឹងបានវិទ្យុគេផ្សាយថាពួកនេះស៊ីស្លឹកឈើ ចាំតែស៊ីស្លឹកឈើតា ស៊ីបាយ ។

បូលីៈ វិទ្យុណាស៊ីស្លឹកឈើ?

បូរីៈ ខាងយើងហ្នឹងណា ។

បូលីៈ ហ៊ូ ខាងហេងសំរិនហេ៎?

បូរីៈ ហ្នឹងហើយ ។

បូលីៈ ផ្សាយថាយើងអត់អីស៊ី ស៊ីស្លឹកឈើ?

បូរីៈ ហ្នឹងហើយ ទៅដល់លើភ្នំសម្បូរណ៍ អត់ខ្វះទេ សព្វថ្ងៃគេបើកឲ្យត បើឲ្យម្នាក់២កំប៉ុង ក្នុង១ថ្ងៃៗ គ្រប់សព្វតែម្ដង ធ្វើនំបញ្ចុកនំអីលាន់ទៅណា ធ្វើនំធ្វើណែកអីអញ្ចឹងទៅណា ។ ពេលបុណ្យទាន គេបើកដំណើប បើកអីឲ្យទៅណា សណ្តែកអី ខ្ញាញ់អញ្ចឹង អត់ខ្វះដែរ ប៉ុន្តែពិបាកៗយើងទៅពីនេះឯង ពេលនៅក្នុងព្រៃនោះ ពេលដើរ ពេលនៅក្នុងព្រៃពួនគេ ហើយតស៊ូនៅម្តុបៗ ពួនគេហ្នឹងណា ។

បូលីៈ ហើយទៅដល់លើភ្នំលែងអីហើយ?

បូរីៈ លែងអីហើយ! នៅ លែងអីតែនៅមួយវគ្គទៀតខ្លាំង ។

បូលីៈ ខ្ញុំយ៉ាងម៉េចទៀតទៅអ៊ឹ?

បូរីៈ ខ្ញុំវាយគ្នា! មួយសារដែលថា ខាងទ័ពខាងយើងទៅវាយ ទន្លេល្ពៅឆ្នាំណាទេ អ៊ឹដូចមិនចាំ ។

បូលីៈ ចុង៨៤?

បូរីៈ វាយខ្ញុំណាស់ណា កាលហ្នឹង ។

បូលីៈ ដេញទៅដីថៃអីកាលនោះ?

បូរីៈ ដេញទៅដីអស់រលីងមួយសារនោះណ៎ ។

បូលីៈ ចុង៨៤ ដើម៨៥?

បូរីៈ ចា៎ស! កាលហ្នឹងអ៊ឹធ្វើកងដឹកជញ្ជូន! ប្រធានកងដឹកជញ្ជូនដែរ យើងអត់បាននៅលើភ្នំទេ គេឲ្យចុះមកក្រោម ស្រួលយកអាក្រប់នោះទៅមុខទៀតអញ្ចឹងណា តែអ៊ឹអត់បានធ្វើអីគេទេ ឈឺ គ្រាន់តែដឹកនាំគេ គ្រាន់តែថាឲ្យយកអីទៅ យើងក៏ចាត់ចែងកម្លាំងទៅៗ ។

បូលីៈ ភ្នំ១០០១ហ្នឹងហ៎អ៊ឹ ពេលហ្នឹងអ៊ឹប្រធានកងដឹកជញ្ជូន?

បូរីៈ ចា៎ស!

បូលីៈ នារី ឬក៏បុរស?

បូរីៈ នារី! សុទ្ធសាច់នារីហើយ ។

បូលីៈ ប៉ុន្មាននាក់ក្នុង១កង?

បូរីៈ មិនដឹងប៉ុន្មានកងតូចទេ! ចង់ភ្លេច ចង់អីអស់ហើយ មានតែជាង១០០ទេ ។

បូលីៈ កងអ៊ឹ ជាង១០០ច្រើនណាស់អញ្ចឹង ។ ប៉ុន្តែមិនមែនមានតែ១កងហ្នឹងទេ?

បូរីៈ មិនមានតែមួយកងហ្នឹងទេ មានខាងភាគកណ្តាលភាគអីទៀត ផ្សេងពីហ្នឹងទៀត ។

បូលីៈ អ៊ឹនេះកងដឹកជញ្ជូននារីរបស់កងពល ឬក៏?

បូរីៈ កងពល ។

បូលីៈ កងពល៨០២?

បូរីៈ ចា៎ស! ទេក្រោយមកវាទៅជា អា៨០២ វរសេនាធំតា, កងពល៨០១ ។

បូលីៈ កងពល៨០១?

បូរីៈ ចា៎ស! អាហ្នឹងទៅជាដឹកជញ្ជូនរួមហើយ មិនមែនវរសេនាធំទេ ។

បូលីៈ ដឹកជញ្ជូននោះយើងដឹកអីខ្លះអ៊ឹ?

បូរីៈ គ្រាប់ អង្ករ ។

បូលីៈ គ្រាប់ អង្ករ?

បូរីៈ ចាស!

បូលីៈ ម្ហូបមានទេ?

បូរីៈ ម្ហូប! អត់ទេ។

បូលីៈ តែគ្រាប់ ហើយអង្ករទេ?

បូរីៈ ចាស!

បូលីៈ សម្ភារផ្សេងៗទៀតមានទេ?

បូរីៈ ទឹកទៅ ដូចអត់មានអីទេ!

បូលីៈ មានតែគ្រាប់ ហើយហ្នឹងអង្ករទេ?

បូរីៈ ចាស!

បូលីៈ ដឹកយកទៅឲ្យទៅកងទ័ពនៅជួរមុខ?

បូរីៈ កងទ័ពនៅជួរមុខ។

បូលីៈ ទៅមួយជើងអញ្ចឹង យើងទៅប៉ុន្មានទាំងអស់គ្នាមួយកង ឬក៏យ៉ាងម៉េច?

បូរីៈ សរុបគ្នាច្រើនដែរ ហើយទៅហ្នឹងនៅមុំពាជង គេហៅអូរធំៗនុះណ៎ា ឃើញអញ្ចឹងចូលជ្រោះ ឡើងពិបាកណាស់ណា ឡើងទៅដល់នេះគេហៅព្រលានគ-៦នោះវាលតែម្តង វាលហើយ បាន ចុះចំណោតមួយតទៅទៀតបានដល់ដីខ្មែរ ដើរពីដីថៃមក។

បូលីៈ ហើយអីយួរម្នាក់ៗប៉ុន្មាន?

បូរីៈ បើ D-K ហ្នឹងតែមួយទេ ម្នាក់មួយៗ Douze-Sept គេហ្នឹងនោះ មួយកេះៗទៅ។ មួយកេះហ្នឹង ទម្រាំដល់យាប់ណាស់ លើកដំបូងដូចស្រាលទេ ចុះមិនមែនឈប់តែម្តងណា ទម្រាំតែដល់ធ្ងន់ទៅៗ យួរទៅៗយកមិនរួចហ្នឹងគេទេ។

បូលីៈ ផ្លូវយើងធ្វើដំណើរហ្នឹង មានចុះភ្នំសម្រុតខ្សែ សម្រុតអីទេ?

បូរីៈ អត់អីទេ! តែឡើងវាចោទ។

បូលីៈ ផ្លូវដើរប៉ុណ្ណា វាធំ?

បូរីៈ ផ្លូវដើរយើងណា។ អត់មានផ្លូវទេះផ្លូវអីណា ផ្លូវដើរក្រឌិចក្រឌុចតាមអីចឹងទៅ ថ្មអីអញ្ចឹងទៅ។

បូលីៈ បាទ! យើងដើរប៉ុន្មានថ្ងៃបានដល់ទីតាំងទាហាន?

បូរីៈ ពេលខ្លះយើងទៅ តាំងពីព្រឹកល្ងាចដល់។

បូលីៈ មួយថ្ងៃអញ្ចឹង?

បូរីៈ ដោយទេ! អាហ្នឹងជិតទេ ពេលខ្លះគេដឹកជញ្ជូនឲ្យសមរភូមិចុះមកដីខ្មែរយូរណាស់ ច្រើនថ្ងៃ ២ ទៅ ៣ថ្ងៃបានដល់ណា ។

បូលីៈ ដូចយើងធ្វើដំណើរមានជួបខបសត្តគេបាញ់ស្ទាក់ ឬក៏ជាន់មីនជាន់អីទេអ៊ំពេលហ្នឹង?

បូរីៈ អត់!

បូលីៈ អត់ទាន់មានទេណ៎?

បូរីៈ អត់! អត់ទេ! ព្រោះថាក្នុងវង្វង់ហ្នឹង ខាងខ្មែរក្រហមគេដើរល្បាតគេដើរអីដែរ ប៉ុនពេលរត់ចេញពីទន្លេល្ពៅមក មានជាន់មីន ជាន់អីគា ដែលគេដេញអីទៅថៃណ៎ ពេលនោះអស់សង្ឃឹមមែនទែន មិនដឹងទៅឯណាទេ រត់៧៩ហ្នឹងម្ដងហើយ ទៅរត់អាហ្នឹងទៀត ។ នឹងឃើញតែប៉ុណ្ណេះចប់ហើយអញ មានគ្រាប់បែកមួយតូច ទៅមុខក៏មិនទៅ ថយក្រោយក៏មិនថយធ្វើម៉េច បើក្លាចទាហានខាងខ្មែរនោះទៅផង អើ! ប្រាប់ថាអញទៅស្លាប់ នឹកឃើញចង់សើចថាហ៎ើបង កុំអាលសិន ចាំមើលគេមើលផងសិន ប្រាប់គេចេះតែឃាត់ ក៏សុខនៅហ្នឹង គេទៅចុះបើគេដើរ ជាក្បួនផង ដឹកជញ្ជូនផង គេថាមីនក្រលង ពេលដល់គេវាយខ្លាំង វាប៉ះដែរដល់ប៉ះទៅធ្វើ ម៉េចអ្នលខ្លះក៏ដួលនៅហ្នឹងទៅ យើងដើរហួសអញ្ចុងទៅពីណាជួយពីណាបើម្នាក់ៗ វាអស់ រលីងពីខ្លួនទៅហើយ យើងដើរទៅទឹកដីថៃនោះណា ។

បូលីៈ បាទ! ដួលស្លាប់នៅ?

បូរីៈ មិនទាន់ស្លាប់ ។

បូលីៈ អត់មាននរណាលើក?

បូរីៈ លើកយ៉ាងម៉េច អ៊ឹស្សូរ? ទាំងក្លួយទាំងអីលើកបានអត់យើងដើរអស់ពេល១ថ្ងៃ ២ថ្ងៃហើយហ្នឹង ហើយមានអីហូបតាមផ្លូវហ្នឹង ហើយភ័យផងអីផង គ្រាន់តែធម្មតាម្ល៉េះសមរភូមិខ្លះគេថាសែងមនុស្សរបួសអី មិន២ គេសែងមុខ សែងក្រោយផ្លាស់គ្នា៥ ទៅ៦នាក់ មិនចង់ដល់ផងចុះទម្រាំនោះទៅសហការណ៍ជាមួយបើ ឡូ នៅពីក្រោយខ្នងនេះ ។ អញ្ចឹងម្ចាស់ការវៀងខ្លួនទៅហ្នឹង ។

បូលីៈ ដែលវៀតណាម វាយបុកឆ្នាំ?

បូរីៈ ហ្នឹងហើយ ។

បូលីៈ ឆ្ងាយទៅទន្លេល្ពៅហ្នឹងអីអ៊ំ?

បូរីៈ ហ្នឹងហើយ! ចា៎ស! ព្រោះកាលហ្នឹងវាចូលទៅក្នុងបាន អញ្ចឹងយើងអត់ដឹង ដល់វាឃើញកម្លាំងទៅច្រើនទៅ បាញ់ឆាំងៗ ត្រូវខ្លះអត់ខ្លះ ចេះតែរុលទៅមុខទៅ រហូតទៅដល់ដីថៃទៅ ។

និយាយពីទៅដល់ដីថៃផ្អើលទៀត ទៅដល់នៅមិនសុខ មិនសាប់ គឺថាទៅទៀតហ៊ូ! រុលទៅដល់ណាដល់ណីនោះ ចេះតែទៅហើយ ទាហានថៃគេដេញមកវិញ ចូលជ្រៅពេកណាស់ អើភ័យចេះតែទៅហើយ ព្រោះពុគ្រាប់ផ្លោង ប៉ុន្តែទៅដល់នោះហើយអត់ខ្វះអីហូបទេ។ កាកបាទគេអីយកទៅជួយដែរ អាទឹកដោះគោ អាដុំៗចេះនោះណា ត្រីខ មីអី គេចែកឲ្យហូបអី នំអីមិនខ្វះទេ។ កាលនោះឡើងទៅអ្នកខ្លះហ៊ឺក ពីណាថាទៅខាងស្អីនោះ ទៅខាងប្រទេសក្រៅណាស់ខ្លះថាមកខាងខ្មែរក្រហមវិញ គេបបួលទៅដែរ ពីណាហ៊ានទៅ បើពុំស្គាល់ពីណាផងខាងនេះមកខាង គ្នាយើងខាងនេះអ្នកស្គាល់។

បូលីៈ បើសិនជាទៅហេងសយ! ថ្ងាលនេះអី ប្រហែលជានៅអាមេរិចនៅអីហើយអឺ?

បូរីៈ ដល់ណាដល់ណីទេ គេមានឡានអីប្រចាំនៅនេះដែលតា។

បូលីៈ ព្រោះអីអ្នកដែលទៅ(ស្តាប់ពុំបាន) ច្រើនតែបានទៅក្រៅ។ ប៉ុនអឺដើរប៉ុន្មានថ្ងៃបានដល់ដីថៃពេលដែលរត់ហ្នឹង?

បូរីៈ ២យប់!ហើយអាខ្លះភ័យពេក កូនបៅដោះថាកូនងាប់ ទម្លាក់កូនហ្នឹង! ទម្លាក់កូនហ្នឹងថ្មថាកូនងាប់ ទៅហើយ! ដល់កងដឹកជញ្ជូនខ្ញុំ ហ្នឹងចេញមុនព្រោះកាលនោះបែក គ្នាហើយណាអ្នកខ្លះនៅដីខ្មែរក្រោម គេទៅតាមក្រោយ ខ្ញុំនៅលើភ្នំ ខ្ញុំចេញមុន ដល់អញ្ចឹងទៅកងដឹកជញ្ជូនខ្ញុំហ្នឹង គឺពរ យកទៅ ខ្ញុំថាអើបើបានមកហើយអត់អីទេ យើងរៀបចំកម្លាំងអញ្ចឹងទៅ គាត់កំពុងរៀបចំ កម្លាំងថាអញ្ចឹងក៏ម៉ែវាមកដល់ ក៏ស៊ីយកទៅវិញទៅ ឲ្យទៅ។

បូលីៈ អភ័ពុគិតទៅណ៎ជីវិត?

បូរីៈ ជួបប្រទះកាលលំបាកច្រើន។

បូលីៈ ៧៥ ទៅ៧៩ វេទនាម្តងហើយ! ស្រាប់ដល់ពេលមក៧៩ មក៨០ជាង រត់ទៀត ដល់តែរត់២ថ្ងៃ ២យប់ យើងក្រែងត្រូវសម្រាកដែលតាអី?

បូរីៈ សម្រាកហ្នឹង សម្រាកហើយនៅតាមផ្លូវហ្នឹងទៅ។

បូលីៈ បានអីទៅ ចងអង្រឹងទៅ?

បូរីៈ ទេ! តាមថ្ម តាមអី ទៅតាមអូរតាមអីទៅ។ មានអង្រឹងណា វាពុំមានកន្លែងណាចងផងបើនិយាយពីព្រៃ ព្រៃស្តុក។ ព្រៃពុំបានយកាំបិត យកអីទៅកាប់ណា នាំគ្នាដេកនៅបន្ទាស់ទើស ជើងទើសដៃ។

បូលីៈ អត់ដែលមានខបដិហេតុទេណា ពស់វែកអីវាមកចឹកទេ?

បូរីៈ អត់ អត់មាន! សុខសប្បាយដែរ។

បូលីៈ ក្នុងព្រៃសុទ្ធតែសត្វហ្នឹងអ៊ំ?

បូរីៈ ឯនោះ អ៊ំអស់កម្លាំងពេកក៏អត់មានស្គាល់ពីដែលដែលថាយើន បងប្អូនយើងនៅក្រចេះនោះ ក៏សួរចុះសួរឡើង ក៏ស្គាល់យើន ស្គាល់អ៊ីចឹងក៏ត្រូវជាបងប្អូនខ្ញុំដែរណ៎ា ឲ្យគេជួយគេស្ពាយ ប្រឡូ ។ ដល់តែស្ពាយចែះទៅហើយ ខ្ញុំចេះតែដើរតាមក្រោយហើយ ទៅរហូតមិនដឹងទៅយ៉ាង ណាទេចេះតែនឹកឃើញក្នុងចិត្ត ដល់ឡើងលើទៅ ទៅជួបគេឲ្យវិញ គេជួយចឹងដែរ ។

បូលីៈ ដលតែពេលទៅដល់ដីថៃ នៅហ្នឹងរយៈពេលប៉ុន្មាន បានយើងចាប់ផ្ដើមធ្វើដំណើរទៅមួយ កន្លែងទៀត?

បូរីៈ អត់ទៀងដែរទេ រួចទៅគេឲ្យកាលហ្នឹងនៅដីថៃដែរណ៎ា ចុងអន្តរនៅម្ដុំដីថៃដែលណា ។ គេឲ្យនៅ ធ្វើជាជំរុំហ្នឹងណា ។

បូលីៈ គេហៅជំរុំអី នៅពេលហ្នឹង?

បូរីៈ ជំរុំក-អំពិល ។

បូលីៈ ក-៧?

បូរីៈ ចា៎ស!

បូលីៈ អាហ្នឹងនៅក្នុង បើគិតមកដីខ្មែរយើង ទល់មុខអី?

បូរីៈ មិនដឹងយ៉ាងណាទេ អ៊ំមិនសូវស្គាល់ភូមិសាស្ត្រ ។

បូលីៈ កាលអ៊ំនៅ១០០១ ស្ថិតនៅក្រោមពីណាគ្រប់គ្រងនៅ១០០១អ៊ំ ម៉ុំ៣?

បូរីៈ ម៉ុំ៣ហ្នឹង តារឿនហ្នឹង ។

បូលីៈ តា០៥?

បូរីៈ ចា៎ស!

បូលីៈ ដល់ពេលរត់មកវៀតណាមវាយបុកមក អ៊ំស្ថិតនៅតែការគ្រប់គ្រងរបស់គាត់ ឬក៏ដូរហើយ?

បូរីៈ ចា៎ស! ដូចអត់ដូរទេ ។

បូលីៈ ដដែរ?

បូរីៈ ចា៎ស! គ្រាន់តែដីថៃ ។

បូលីៈ អ៊ំដែលឮសូរស៊ឺងចាន់ ជប់មួរ អូរគ្រាវទេអ៊ំ?

បូរីៈ ដឹងតា! អាហ្នឹងខាង មិនមែនខាងខ្មែរក្រហមទេ! អូរគ្រាវ ដូចជាមិនដឹងជំរុំខាងណាទេនេះ ។ ស៊ឺងចាន់អ៊ីខាងនេះហេ៎ ខាងរណបុទ្ធិហី ហ្នឹងហើយខាងស៊ឺងចាន់ រណប្សិហើយ គណៈបក្ស ហ៊ុន ស៊ិនប៉ិចនោះ ។

បូលី៖ អឺ គ-៧?

បូរី៖ ចា៎ស!

បូលី៖ នៅក្នុងខេត្តអីរបស់ថៃហ្នឹង បើយើងគិតខេត្តវិញ? យើងអ៊ូប៊ុន ចេញពីអ៊ូប៊ុនមក ស៊ីសាកេត?

បូរី៖ ម៉ុំស៊ីសាកេត ខាងតាលាក់ ព្រោះមេធំដែលនៅនោះ ដូចខយុនហ៊ាន ឬស៊ីសាកេតទេ ទៅដល់ដីថៃ ដល់ពេលចេញមកវិញ ចូលផ្សារខាងតាលាក់ ខាងអីដែរ ។ ពេលដែលទៅដល់ថៃដំបូងលើកទីមួយដែលយើងទៅណា៎ ឡានអីគេមកចាំហ៎ូយើញភ្លើង ចុះពេលយើងនៅពេលយូរនោះខានឃើញភ្លើងនោះ ឃើញរំភើប! ឃើញអាភ្លើងស្អាតតែម្ដង! អាឡានគេកុងទីន័រធំៗហ្នឹងភ្លើង ចុះឡានថៃផងគេមិនតុបតែង ភ្លើងគេនោះ ។

បូលី៖ ឡានគេមកចាំយកយើង?

បរី៖ ចាំយកយើងទៅត្រង់នេះ តែយើងតែងខ្លួន របៀបមិនស្លៀកខោអាវខ្មៅទេ អាហ្នឹងវាប្រែភាពតិចៗហើយដល់ពេលនោះមានស្លៀកអាសំពត់អាស៊ីបអាអាវនោះ រឿងអាវការអាវអី ហើយចូលទឹកដីថៃហ្នឹងណា ។

បូលី៖ ពេលដែលយើងនៅម៉ុំពហ្នឹងយើងស្លៀកពាក់ខ្មៅ ឬក៏ប្រែភេទខ្លះៗហើយ?

បូរី៖ អត់ខ្មៅទេ! មានពណ៌ក្រហម ពណ៌ខៀវ ពណ៌បតងអីអញ្ចឹងទៅណា មានមួយពណ៌ៗចឹង តែវាអត់មានអាវផ្កាទេ អត់មានក្រណាត់ផ្កាទេ តែដល់ពេលទៅអញ្ចឹង គេទិញក្រណាត់អាវទៅ ទិញអីអញ្ចឹងទៅណាស់ យកមកកាត់ទៅ ស្លៀកទៅ ។

បូលី៖ អឺទៅនៅគ-៧ហ្នឹង បានរយៈពេលប៉ុន្មាន?

បូរី៖ អឺអត់ចាំទេ! មិនឆាប់ទេ ប្រហែល១ឆ្នាំ ២ឆ្នាំទេដឹង ។

បូលី៖ បាទ! ចេញពីហ្នឹង ទៅណាទៀតទៅ ពីគ-៧ទៅ?

បូរី៖ គ-៧ទៅត្រលប់មកនេះវិញហើយ ។

បូលី៖ មកទីណាទៅ?

បូរី៖ មកនេះវិញហើយ មកអ៊ុនតាក់នោះ មួយសារអ៊ុនតាក់នោះ ។

បូលី៖ ហ៎ូ! ៩១ កិច្ចព្រមព្រៀងទីក្រុងប៉ារីសហើយ?

បូរី៖ ៩២! ខ្ញុំមកនៅនេះហើយ មកនៅនេះ ចុះមកនៅនេះ ។ ចុះមកនេះហើយ ដល់ទាហានវាយហើយឡើងទៅវិញទៀត ។

បូលី៖ មកនេះហ្នឹង អឺចង់ថានៅឃុំអីទៀត?

បូរី: នេះហើយត្រពាំងប្រាសាទនេះឯង ក្រោយPM នេះ នៅទីហ្នឹងៗ ដល់ពេលគេបកមកវាយទៀត បកទៅវាយទៀតនាំគ្នារត់ទៅកន្លែងឈូករុនៗ កាលហ្នឹងគេវាយ ខ្លាំងហើយ ហើយខ្លាំងអន្លង់វែងហ្នឹង!

បូលី: ទៅមកៗអ៊ី?

បូរី: ទៅមកៗ! បើថានៅក្នុងព្រៃវិញ មិនមែនផ្ទះអីយើងស្រួលបួលទេណា កាលនៅម្តុំមុំពាអាហ្នឹងមានផ្ទះ អាហ្នឹងមានផ្ទះ មានផ្ទះខ្ពស់ៗប្រក់ស្បូវប្រក់អីចឹងដែរ ក៏ប៉ុន្តែសភាពការខ្លាំង ពួកខ្ញុំអត់មានផ្ទះទេ មានខ្ទមយើងដូចថាពនយើងទៅទយគូថឡើងអង្គុយដេកហ្នឹងណា ពេលខ្លះយប់ឡើងស្តាយក្រឡស្តាយ ទៅដេកនៅទីណាបន្តិចទៅ អញ្ចឹងក្លាចគេៗ

បូលី: ពេលមកនៅត្រពាំងប្រាសាទ ហ្នឹងអ៊ី?

បូរី: កាលនៅព្រៃៗ

បូលី: ព្រៃហ៎?

បូរី: ចា៎ស! ដល់ដីថៃហើយក៏ដោយ ក៏នៅតែពួនដែរ ដូចថាដានជើងត្រង់ៗណានាំគ្នាត្រៀមនៅនោះវិញៗ

បូលី: ចុះពេលដែលអ៊ឺ ចុះមកត្រពាំងប្រាសាទនេះវិញ យើងមានសង់អីផ្ទះនៅ ៩២ហ្នឹង?

បូរី: ៩២ៗ

បូលី: បាទ!

បូរី: ៩២ហ្នឹងសង់ ខ្ញុំសង់ផ្ទះនៅកន្លែងនោះ មុខPM ខាងនោះ PM តិច! សង់ផ្ទះខ្ពស់ដែរប្រក់ស្បូវហ្នឹងឯងៗ ជញ្ជាំងអី វាមិនជុំជិតទេណា ដល់ទាហានវាមកវាយអន្លង់វែងហ្នឹង ក៏ចោលហ្នឹងទៅទៀតទៅណា គេដុតចោលទៅណាៗ

បូលី: គេដុតផ្ទះចោល?

បូរី: ដុត! ដុតទាំងអស់ៗ

បូលី: ម៉េចបានចាំបាច់ដុត?

បូរី: ដឹង! មិនបានសួរខាងហ្នឹងៗ បើសង្គ្រាមវាយគ្នា មិនដុត ដុតមិនឲ្យយើងមានជម្រកនៅនោះៗ

បូលី: អូ៎! ខាងនោះគេអ្នកដុតហ៎? មិនមែនយើងអ្នកខ្លួនឯងអ្នកដុតទេ?

បូរី: ហ៎! បានអីដុត បើរត់យកយោងតែអត្មា ចង់មិនទាន់ផងៗ

បូលី: ខាងអន្លង់វែង តាម៉ុក បញ្ជាឲ្យដុតចោលតែម្តង?

បូរី: អាហ្នឹងគេធ្វើកន្លែងធំៗជាងគេ ធំជាងនៅនេះ!

បូលីៈ នៅអន្លង់វែង តាម៉ុក គាត់គ្រប់គ្រងចុះ ត្រពាំងប្រាសាទនរណាគេគ្រប់គ្រង?

បូរីៈ ត្រពាំងប្រាសាទ អ៊ឹខៀវ ។

បូលីៈ តាខៀវ?

បូរីៈ សុន សេន។ សុន សេន តែគាត់មិននៅក្រោមជាប់ដូច តាម៉ុក គាត់នៅលើភ្នំ គាត់នៅជិត ប៉ុល ពត ហ្នឹងណា មានតែកងពលមានតែហ្នឹង គាត់បញ្ជាហ្នឹងណា ។

បូលីៈ អ៊ីរត់ឡើងទៅលើហ្នឹង រត់ទៅរយៈពេលយូរទេបានចុះមកវិញ?

បូរីៈ គិតមើលតាំងពី ៧៩ ។

បូលីៈ នៅពេលដែលរដ្ឋាភិបាលវាយចូល ដុតផ្ទះចោល ។

បូរីៈ ដុតផ្ទះចោលខ្ញុំឡើងទៅនោះ ហើយចុះមកវិញ រត់ទៅខាងអូរស្មាយនោះ។ ទៅខាងអូរស្មាយ ហើយកាលនោះឈ្លោះគ្នាផង ។

បូលីៈ នរណា ឈ្លោះជាមួយនរណា?

បូរីៈ តាម៉ុក ជាមួយ ប៉ុល ពត ។

បូលីៈ ឈ្លោះរឿងអី?

បូរីៈ មិនដឹងឈ្លោះរឿងអីគេទេ អ្នកធំនោះ។ ខ្ញុំឃើញការសែតកាលនោះ ភ្លូកទឹក ភ្លូកដីថាគេ បាញ់ សុន សេន ហ្នឹង ។

បូលីៈ បាទ! ខ្ញុំដឹងដែររឿងហ្នឹង ។

បូរីៈ ដល់នេះគេសម្លាប់ សុន សេន, តាម៉ុក បញ្ជាទ័ពឡើងដេញ ប៉ុល ពត។ រួចហើយគេក៏ចាប់ ប៉ុល ពត មកណា ។

បូលីៈ នរណាអ្នកស្លាប់?

បូរីៈ សុន សេន ស្លាប់ទាំងប្តី ទាំងប្រពន្ធ កូន កូនប្រសារចៅអីទាំងអស់ ។

បូលីៈ នរណាគេអ្នកសម្លាប់គាត់?

បូរីៈ មិនដឹងនរណាគេទេ ។

បូលីៈ មិនមែនតាម៉ុកទេ?

បូរីៈ អត់ទេ! មិនមែនតាម៉ុកទេ! ជាមួយ សុន សេនត្រូវគ្នាទេ ។

បូលីៈ តែយើងអត់ដឹងថានរណាអ្នកធ្វើទេ?

បូរី៖ គេថាអ្នកចោទថា ប៉ុល ពត ៗ ប៉ុន្តែ មិនដឹងមែនអត់ណាស់ មិនដឹងច្បាស់ដែរ ។ កាលនោះបើគេត្រៀមធ្វើរដ្ឋាភិបាលគា មានផែនការដែល មានកាន់ការដែរ ប៉ុនមិនមិនដឹងយ៉ាងម៉េចទៅវ៉ាយគ្នាមុន ឈ្លោះគ្នាមុនទៅ ។ ហើយអ៊ំនិយាយហ្នឹងប្រហែលគេឆ្លើយអត់ ។

បូលី៖ បាទ! ស្រដៀងៗគ្នាអ៊ី?

បូរី៖ ជីវភាពនៅលើភ្នំ កងទ័ពទៅមុខទៅ ប្រពន្ធធ្វើស្រែ ធ្វើចម្ការ ប៉ុនគេអង្ករឲ្យអីយើងហូបដែរស្អរអីគេឲ្យ ។

បូលី៖ ការរៀនសូត្រកូនចៅក្មេងៗអី?

បូរី៖ កាលនោះអត់បានទេ! មានពេលណារៀនបើទឹកន្ទែងមិនគត់មុតអញ្ចឹង ម្តងទៅនេះម្តងទៅនោះត្រៀមតែរហូតនោះ ធ្វើផ្ទះធ្វើក៏ធ្វើទៅទេ បាននៅក៏បាន មិនបាននៅក៏ទៅ ។

បូលី៖ ទំនាក់ទនងអី អ្នកដែលរស់នៅក្បែរៗគ្នាអីយ៉ាងម៉េចដែរអ៊ំ?

បូរី៖ សាមគ្គីគ្នាល្អគា!

បូលី៖ សាមគ្គីគ្នាណ៎?

បូរី៖ ចា៎ស!

បូលី៖ ហើយពេលដែលយើងនៅត្រពាំងប្រាសាទឆ្នាំ៩០ជាងអីហ្នឹង យើងមានវត្តមានលោកអីទេអ៊ំ?

បូរី៖ ទេ! មករបៀបថាមកមួយសារអ៊ីនគាក់ មួយភ្លែតហ្នឹង ធ្វើផ្ទះនោះបានក៏ចេញពីហ្នឹងទៀតមិនអញ្ចឹងទេ ក៏រៀបវត្តវ៉ា ។ ចុះមិនមែនទឹកដីយើងដែលថា កំណត់យើងថាយើងនៅ បានឯណា អាម៉េចរៀបចំអីកើត ។ ទើបតែចុះមកពីហ្នឹងវិញឆ្នាំប៉ុន្មានទេ បានរៀបចំសាលាបានខ្លះដែរ កាលនៅអូរស្មាយ ។

បូលី៖ បានសាលាអីខ្លះកាលហ្នឹងអ៊ំ?

បូរី៖ ថ្នាក់ទី១ ទី២ហ្នឹងណា កូនក្មេងរៀនហ្នឹងណា ។

បូលី៖ មានជាអាគារសាលាទេ?

បូរី៖ អត់ទេ! អាគារឯណា រកតែផ្ទះនៅពុំបានផង មាននរណាទៅជួយ មាននរណាទៅធ្វើឲ្យ ។

បូលី៖ រៀនយ៉ាងម៉េចទៅ?

បូរី៖ រៀនតាមផ្ទះ ចេះៗ ប្រកស្បូវទៅណា រៀនទៅណា ។

បូលី៖ តាមផ្ទះប្រជាជន?

បូរី៖ ទេ! គេធ្វើសាលាគេដែរ ។

បូលី៖ គ្រាន់តែថាមិនមែនជាអាគារធំដុំទេ?

បូរី៖ រោងដោល! តូចអញ្ចឹងទៅណា ។

បូលី៖ ចុះសុខភាពប្រជាជនអីយ៉ាងម៉េចដែរអ៊ំពេលរស់នៅហ្នឹង?

បូរី៖ សុខភាពដូចអត់អីដែរ ។ គេមានពេទ្យ តាមអង្គភាពតាអីគេដែរ តាមកងពល តាមវរសេនាធំ ។

បូលី៖ ពេទ្យហ្នឹង គេរៀនតាមវិជ្ជាគេដែរ?

បូរី៖ ស្អីតា!

បូលី៖ តាដួន ជឿន?

បូរី៖ តាដួនជឿនពូកែណាស់ណ៎ ។ តាដួនជឿននៅជួយ ប៉ុល ពត នៅឯលិចនោះ បើកាលណាគេឈឺធ្ងន់ធ្ងរ គេទៅហ្នឹង ឬមួយក៏ទៅថៃ ។

បូលី៖ ប៉ុន្តែ ដួន ជឿន តែម្នាក់ឯងអញ្ចឹង ហើយប្រជាជនរាប់សែននាក់?

បូរី៖ ទេ! គេមានគ្នាគេដែរតា ក្រុមពេទ្យគេមាន គេរៀបចំពេទ្យ ពេទ្យបានរៀបចំល្អ បើសាលាវិញមិនសូវដែរទេ ។ ពេទ្យដល់ឈឺ យើងទៅដេកពេទ្យដែរតា ។ គេសង់មន្ទីរពេទ្យអីស្រួលបួលគេតា ។ អ្នកវះខ្នែង វះអីលាន់ហ្នឹង របួសអីគេកាត់ខ្លួនគេហ្នឹង ។ អញ្ចឹងបានថាពេទ្យអត់ចោលទេ ។

បូលី៖ មិនមានជាបញ្ហាចោទទេ?

បូរី៖ ព្រោះអីខ្ញុំមើលឃើញ ការវះកាត់ ក៏គេវះបាន វះខ្នែងវះអី កាលនោះសម្បូរណ៍មនុស្សខ្នែងទៀត ពោះវៀនខ្នែង ហើយកំបុតជើងកំបុតដអញ្ចឹងទៅ ។ គេក៏រៀបចំអ្នកព្យាបាលព្យាអីមានពេទ្យមានអីត្រឹមត្រូវរបស់គេ មានប្រធានមានអីគេ ។

បូលី៖ បាទ! អ៊ំគិតថា ការឆ្លងកាត់ការរស់នៅសម័យខ្មែរក្រហមរបស់អ៊ំ ក៏ដូចជានៅក្នុងព្រៃ លើភ្នំវាមានផលប៉ះពាល់អីខ្លះ ដល់ជីវិតរស់នៅរបស់អ៊ំរាល់ថ្ងៃនេះ?

បូរី៖ ប្រៀបធៀបហ៎?

បូលី៖ បើសិនជាដូចថា បើអត់មានរបបហ្នឹង ជីវិតដូចថាវាយ៉ាងម៉េច ហើយដោយសាររបបហ្នឹងបានជីវិតរបស់អ៊ំវាទៅជាយ៉ាងម៉េច បើអត់មានខ្មែរក្រហមវិញណា?

បូរី៖ បើអត់មានខ្មែរក្រហម អ៊ំក៏មិនបានមកដល់នេះដែរ ព្រោះមិនមែនជាស្រុកភូមិយើងណា ខ្ញុំនៅតែស្ទឹងត្រែង ម៉េចបានស្គាល់នេះ ។

បូលី៖ អ៊ំគិតថាវាបានធ្វើឲ្យប៉ះពាល់យ៉ាងម៉េចដល់ជីវិតរបស់អ៊ំ នៅក្នុងរបបខ្មែរក្រហម ឬក៏អ៊ំមានមានការសោកស្តាយទេ ឬក៏វាល្អ?

បូរីៈ ទេ! កាលនោះវាភ័យព្រួយដែរ មួយសារដែរគេថា អានេះក៏ក្បត់ អាននោះក៏ក្បត់ វាភ័យដែរនោះ ។ ភ័យដែរបារម្ភដែរ អត់មានអីប៉ះពាលអឹទេ ព្រោះនរណាធ្វើប្រធាន គឺបាត់ខ្លួនហើយ ដល់អញ្ចឹងយើងខ្លាចដែរហ្នឹងណា ។

បូលីៈ ចុះកាលហូបចុក មុនសម័យខ្មែរក្រហម ក្រោយសម័យខ្មែរក្រហមក្នុងកំឡុងពេលសម័យខ្មែរក្រហម ហើយក្រោយសម័យខ្មែរក្រហមទៀត វាមានការផ្លាស់ប្ដូរទេ ការហូបចុករបស់មីងណា?

បូរីៈ កាលនៅសម័យខ្មែរក្រហម មានអីហូប មានតែត្រីខហូបហ្នឹង! សម្លកូរ ត្រីខ ។

បូលីៈ ចុះក្រោយមក ហើយហ្នឹងមុនសម័យខ្មែរក្រហម យ៉ាងម៉េចដែរអឹ?

បូរីៈ សម័យខ្មែរក្រហមជីវភាពយើងនៅផ្ទះយើង មានអីពិបាក ។

បូលីៈ ដល់ក្រោយសម័យខ្មែរក្រហម?

បូរីៈ ក្រោយខ្មែរក្រហម ឥឡូវមានអី! ស្រួលតា ចង់ដេក ដេក! ចង់ដើរ ដើរ! ចង់ស៊ី ស៊ីទៅ! ចង់ធ្វើ ធ្វើទៅ!

បូលីៈ អត់មានបញ្ហាអីធ្ងន់ធ្ងរទេអឹ?

បូរីៈ អត់ទេ!

បូលីៈ ហើយ! សព្វថ្ងៃនៅក្នុងភូមិស្រុកយើងអី ទំនាក់ទំនងប្រជាជនពីមួយគ្រួសារទៅមួយគ្រួសារយ៉ាងម៉េចទៅអឹ?

បូរីៈ នៅនេះ ។

បូលីៈ បាទ!

បូរីៈ អត់អីទេ! មានការប្រាស្រ័យទាក់ទ្នាគា ។

បូលីៈ មានការរើសអើងគ្នា ឬមួយទំនាស់គ្នាទេ តពីមុនមក?

បូរីៈ អត់មានទេ! អត់មាននរណាប្រកាន់នរណាទេ ដូចថាឆ្លងកាត់ពីខ្មែរក្រហមមកនេះ មានបំណងមកនោះ អត់មានទេ គេបញ្ចប់ ។

បូលីៈ អញ្ចឹងដូចជាមានសំនួរតែប៉ុណ្ណឹងទេអឹ សួរអឹ ច្រើនម៉ោងដែរ កុំឲ្យរំខានអីយូរ អឹសុខភាពពុំសូវបានផង ។

បូរីៈ ធ្វើម៉េចអឹឆ្លើយខុសត្រូវយ៉ាងម៉េចដែរ ។

បូលីៈ អត់ទេ! អឹឆ្លើយទៅតាមការដែលការពិតដែលអឹដឹង ខ្ញុំយកព័ត៌មានទាំងអស់នោះទៅ ទាំង៣ទៅ៤០០ សម្ភាសន៍ហ្នឹង យកទៅយើងស្រង់យកចំណុចនាដែលគេដឹងយករបស់គេទៅ ហើយ

របស់ណាដែរគេអត់ដឹង យករបស់ងអឺ សំយោគចូលគ្នាទៅ បានចេញជាសៀវភៅអញ្ចឹង កើត ។

បូរី៖ អានេះចុះសម្ទេងអឺតិចមើល ។

បូលី៖ បាទ! អឺបាទ ។

«ចប់»